ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៧ សហវ.

2140
04-09-2024

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ប្រាក់ឧបត្ថម្ភអាហារសិស្ស ប្រាក់ឧបត្ថម្ភចុងភៅ វិធីសាស្ត្រកំណត់ចំនួនសិស្សត្រូវទទួលអាហារនិងចំនួនចុងភៅ និងផ្ទះបាយសាលារៀន ក្រោមកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីប្រាក់ឧបត្ថម្ភសម្រាប់អាហារសិស្ស ប្រាក់ឧបត្ថម្ភសម្រាប់ចុងភៅ វិធីសាស្ត្រកំណត់ចំនួនសិស្សត្រូវទទួលអាហារ វិធីសាស្ត្រកំណត់ចំនួនចុងភៅ និងកំណត់ប្រភេទ និងតម្លៃឯកតាផ្ទះបាយសាលារៀន ក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ នៅតាមសាលាបឋមសិក្សាសាធារណៈគោលដៅ ដែលត្រូវបានជ្រើសរើសដាក់ឱ្យអនុវត្តកម្មវិធី។

**ប្រការ២.-**

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ មានដូចខាងក្រោម៖

- **ការបង្រៀន និងរៀនពេញមួយថ្ងៃ** សំដៅដល់សកម្មភាពសិក្សារបស់សិស្ស ក្នុងសាលាបឋមសិក្សាសាធារណៈគោលដៅតែមួយ ដែលតម្រូវឱ្យសិស្សទាំងអស់រៀននៅវេនព្រឹក និងវេនរសៀល។
- **ការបង្រៀន និងរៀនមួយវេន** សំដៅដល់សកម្មភាពសិក្សារបស់សិស្សក្នុងសាលាបឋមសិក្សាសាធារណៈគោលដៅតែមួយ ដែលតម្រូវឱ្យសិស្សភាគខ្លះរៀននៅវេនព្រឹក សិស្សភាគខ្លះរៀននៅវេនរសៀល ឬសិស្សភាគខ្លះរៀនឆ្លាស់វេនគ្នា។
- **ផ្ទះបាយសាលារៀន** សំដៅដល់កន្លែងចម្អិនអាហារ ដោយមានឃ្លាំងទុកសម្ភារៈ។ ផ្ទះបាយសាលារៀន មានគំនូសប្លង់ ៣ប្រភេទ គឺប្រភេទ១៖ ផ្ទះបាយសាលារៀនខ្នាតតូច ប្រភេទ២៖ ផ្ទះបាយសាលារៀនខ្នាតមធ្យម និង ប្រភេទ៣៖ ផ្ទះបាយសាលារៀនខ្នាតធំ។

## ជំពូកទី២

## ប្រាក់ឧបត្ថម្ភអាហារសិស្ស និងវិធីសាស្ត្រកំណត់ចំនួនសិស្សត្រូវទទួលអាហារតាមប្រភេទសាលារៀន និងតាមវេនសិក្សានីមួយៗ

**ប្រការ៣.-**

សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀន និងរៀនមួយវេន ឬពេញមួយថ្ងៃ ត្រូវផ្តល់អាហារចំនួនមួយពេល ជូនដល់សិស្សទាំងអស់ដែលមានវត្តមាននៅថ្ងៃសិក្សាតាមវេន នីមួយៗ។ សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀន និងរៀនមួយវេន ត្រូវផ្តល់អាហារពេលព្រឹក។ សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ ត្រូវផ្តល់អាហារពេលថ្ងៃត្រង់។

ការផ្ដល់ជូននេះ ត្រូវគិតបញ្ចូលទាំងសិស្សថ្នាក់មត្តេយ្យសិក្សា ដែលកំពុងរៀននៅក្នុងសាលាបឋមសិក្សាសាធារណៈគោលដៅ និង/ឬ សាលាមត្តេយ្យសិក្សា ដែលមានទីតាំងក្នុងបរិវេណជាមួយសាលាបឋមសិក្សាសាធារណៈគោលដៅ។

**ប្រការ៤ ._**

សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀននិងរៀនមួយវេន ត្រូវទទួលបានប្រាក់ឧបត្ថម្ភរបបអាហារសិស្ស ៨២០ (ប្រាំបីរយម្ភៃ)រៀល សម្រាប់សិស្សម្នាក់។

សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃ ត្រូវទទួលបានប្រាក់ឧបត្ថម្ភរបបអាហារសិស្ស ១ ៣០០ (មួយពាន់បីរយ)រៀល សម្រាប់សិស្សម្នាក់។

**ប្រការ៥ ._**

សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀននិងរៀនមួយវេន ឬពេញមួយថ្ងៃ ត្រូវទទួលបានប្រាក់ឧបត្ថម្ភរបបអាហារសិស្ស សម្រាប់រយៈពេល១០ (ដប់)ខែ ឬមានរយៈពេលអតិបរមា ២១០ (ពីររយដប់) ថ្ងៃ ក្នុងមួយឆ្នាំសិក្សា ឬតាមរយៈពេលជាក់ស្តែងក្នុងឆ្នាំសិក្សា។

**ប្រការ៦ ._**

ការកំណត់ចំនួនសិស្ស ត្រូវទទួលរបបអាហារនៅតាមវេនសិក្សា ក្នុងសាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀននិងរៀនមួយវេន ត្រូវកំណត់ដោយផលគុណអប្បបរមា ៧៥% នៃចំនួនសិស្សបឋមសិក្សាសរុប បូកជាមួយចំនួនសិស្សមត្តេយ្យសិក្សា ១០០% ដែលកំពុងរៀននៅក្នុងសាលាបឋមសិក្សាសាធារណៈគោលដៅ និង/ឬ សាលាមត្តេយ្យសិក្សា ដែលមានទីតាំងនៅក្នុងបរិវេណជាមួយសាលាបឋមសិក្សាសាធារណៈគោលដៅតែមួយ។

**ប្រការ៧ ._**

ការកំណត់ចំនួនសិស្ស ត្រូវទទួលរបបអាហារនៅតាមវេនសិក្សា ក្នុងសាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃ គឺជាផលគុណ ១០០% នៃចំនួនសិស្សបឋមសិក្សាសរុប បូកជាមួយចំនួនសិស្សមត្តេយ្យសិក្សា ១០០% ដែលកំពុងរៀននៅក្នុងសាលាបឋមសិក្សាសាធារណៈគោលដៅ និង/ឬ សាលាមត្តេយ្យសិក្សា ដែលមានទីតាំងនៅក្នុងបរិវេណជាមួយសាលាបឋមសិក្សាសាធារណៈគោលដៅតែមួយ។

**ប្រការ៨ ._**

ការកែសម្រួលប្រាក់ឧបត្ថម្ភរបបអាហារសិស្ស ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការស្នើសុំរបស់ក្រសួងអប់រំ យុវជន និងកីឡា អាស្រ័យលើស្ថានភាពសង្គម សេដ្ឋកិច្ច ភាពទ្រទ្រង់បាននៃថវិកាជាតិ និង/ឬ តាមការចាំបាច់។

## ជំពូកទី៣
## ប្រាក់ឧបត្ថម្ភចុងភៅ និងវិធីសាស្ត្រកំណត់ចំនួនចុងភៅ
## តាមប្រភេទសាលារៀន

**ប្រការ៩ ._**

ប្រាក់ឧបត្ថម្ភចុងភៅ នៅតាមសាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀននិងរៀនមួយវេន ត្រូវបានផ្តល់ជូនចំនួន ២០០ ០០០(ពីររយពាន់)រៀល ក្នុងមួយខែ សម្រាប់ចុងភៅមួយនាក់។

ប្រាក់ឧបត្ថម្ភចុងភៅ នៅតាមសាលាបឋមសិក្សាសាធារណៈគោលដៅ ដែលអនុវត្តការបង្រៀន

និងរៀនពេញមួយថ្ងៃ ត្រូវបានផ្តល់ជូនចំនួន ៣០០ ០០០(បីរយពាន់)រៀល ក្នុងមួយខែ សម្រាប់ចុងភៅមួយនាក់។

**ប្រការ១០ ..**

ការផ្តល់ប្រាក់ឧបត្ថម្ភចុងភៅ នៅតាមសាលាបឋមសិក្សាសាធារណៈគោលដៅ ត្រូវបានបើកផ្តល់ជាប្រចាំខែ។ ការឧបត្ថម្ភនេះ មានរយៈពេល១០ (ដប់)ខែ និង/ឬ តាមរយៈពេលជាក់ស្តែងក្នុងឆ្នាំសិក្សា។

ការបើកផ្តល់ប្រាក់ឧបត្ថម្ភចុងភៅ ត្រូវធ្វើឡើងរវាងសាលាបឋមសិក្សាសាធារណៈគោលដៅ និងចុងភៅ នៅមុនដំណាច់ខែនីមួយៗនៃឆ្នាំសិក្សា ដូចមានចែងក្នុងកិច្ចសន្យា។

**ប្រការ១១ ..**

ការកែសម្រួលប្រាក់ឧបត្ថម្ភចុងភៅ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការស្នើសុំរបស់ក្រសួងអប់រំ យុវជន និងកីឡា អាស្រ័យលើស្ថានភាពសង្គម សេដ្ឋកិច្ច ភាពទ្រទ្រង់បាននៃថវិកាជាតិ និង/ឬ តាមការចាំបាច់។

**ប្រការ១២ ..**

ចំនួនចុងភៅ អាចត្រូវជ្រើសរើសនៅតាមសាលាបឋមសិក្សាសាធារណៈគោលដៅ ដូចខាងក្រោម៖

- សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលមានសិស្សហូបអាហារ ស្មើឬតិចជាង ១៤៩នាក់ អាចមានចុងភៅ ២នាក់
- សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលមានសិស្សហូបអាហារ ចន្លោះពី ១៥០-២៤៩នាក់ អាចមានចុងភៅ ៣នាក់
- សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលមានសិស្សហូបអាហារ ចន្លោះពី ២៥០-៣៤៩នាក់ អាចមាន ចុងភៅ ៤នាក់
- សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលមានសិស្សហូបអាហារ ចាប់ពី ៣៥០នាក់ឡើងទៅ អាចមានចុងភៅ ៥នាក់។

លក្ខខណ្ឌ និងនីតិវិធីលម្អិតនៃការជ្រើសរើសចុងភៅ ត្រូវកំណត់នៅក្នុងសៀវភៅណែនាំប្រតិបត្តិការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍។

## ជំពូកទី៤
## ផ្ទះបាយសាលារៀន

**ប្រការ១៣ ..**

ប្រភេទផ្ទះបាយសាលារៀន ត្រូវបានកំណត់ ដូចខាងក្រោម ៖

-ប្រភេទ១ ៖ សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលមានសិស្សហូបអាហារស្មើ ឬតិចជាង ១៤៩នាក់

-ប្រភេទ២ ៖ សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលមានសិស្សហូបអាហារចន្លោះពី ១៥០ ទៅ ៣៤៩នាក់

-ប្រភេទ៣ ៖ សាលាបឋមសិក្សាសាធារណៈគោលដៅ ដែលមានសិស្សហូបអាហារចាប់ពី ៣៥០ នាក់ ឡើងទៅ។

ប្រភេទផ្ទះបាយសាលារៀន មានតម្លៃឯកតាអតិបរមា ដូចខាងក្រោម៖

-ប្រភេទ ១ ៖ តម្លៃ ២០ ០០០ ០០០(ម្ភៃលាន)រៀល សម្រាប់ផ្ទះបាយមួយកន្លែង

-ប្រភេទ ២ ៖ តម្លៃ ២៥ ២០០ ០០០(ម្ភៃប្រាំលាន ពីររយពាន់)រៀល សម្រាប់ផ្ទះបាយមួយកន្លែង

-ប្រភេទ ៣ ៖ តម្លៃ ៣០ ០០០ ០០០(សាមសិបលាន)រៀល សម្រាប់ផ្ទះបាយមួយកន្លែង។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ១៤ ..**

ប្រកាសនេះ ត្រូវមានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ ..**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

លេខ ១៥៦២ អយក.ចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ថតចម្លង

បញ្ជូនមក៖ -គ្រប់អង្គភាពនិងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួង

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត

"ដើម្បីមុខការ និងអនុវត្តន៍"

ថ្ងៃ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០២៤

**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

**នេព_តិយ៉ោវ៉ារិទ្ធ**